# សុន្ទរកថា

# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែង

# នៅក្នុងពិធីបើកសន្និសីទជាតិស្តីពីការអភិវឌ្ឍន៍វិស័យ

# មីក្រូហិរញ្ញវត្ថុនៅកម្ពុជា

# នៅវិមានសន្តិភាព ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦

*- សម្តេច ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អង្គពិធីទាំមូលជាទីមេត្រី !*

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយ ដោយបានមកចូលរួមក្នុងពិធីបើក***«សន្និសីទជាតិស្តីពីការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា»*** ដែលបានប្រារព្ធឡើងនាពេលនេះ ។ គិតមកដល់ពេលនេះ គឺមានរយៈពេល ១០ ឆ្នាំគត់ បន្ទាប់ពីសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជាត្រូវបានប្រារព្ធឡើងកាលពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០០៦ ដែលយើងបានប្រកាសថា ឆ្នាំ ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ហើយពេលនេះយើងបានមកជួបជុំគ្នាជាថ្មីម្តងទៀត ដើម្បីអបអរសាទរសមិទ្ធផលដែលសម្រេចបាន ព្រមទាំងត្រៀមខ្លួនដោះស្រាយបញ្ហាប្រឈមចំពោះមុខថ្មីៗទៀត



ក្នុងបុព្វហេតុបន្តជំរុញការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាឱ្យកាន់តែរីកចម្រើន ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងការកោតសរសើរចំពោះធនាគារជាតិនៃកម្ពុជា ដែលបានផ្តួចផ្តើមរៀបចំសន្និសីទនេះឡើងក្នុងគោលបំណងជម្រាបជូនសាធារណជនជាតិ និងអន្តរជាតិអំពីវឌ្ឍនភាពក្នុងការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាក្នុងរយៈពេលមួយទសវត្សរ៍កន្លងមក ក៏ដូចជាការបន្តពង្រឹងនូវជំនឿទុកចិត្តរបស់សាធារណជនទូទៅមកលើប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ។ ខ្ញុំក៏សូមកោតសរសើរចំពោះធនាគារជាតិនៃកម្ពុជា និងដៃគូពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកដល់ការអភិវឌ្ឍន៍វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាឱ្យមានការរីកចម្រើនយ៉ាងឆាប់រហ័ស ទាំងទំហំមូលធន និងវិសាលភាពគ្របដណ្តប់ ។

ជាក់ស្តែង វិស័យធនាគារនៅកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការកៀរគរប្រាក់សន្សំរបស់សាធារណជន និងប្រភពទុនផ្សេងៗទៀតនៅក្នុងទីផ្សារអន្តរជាតិមកចាក់បញ្ចូលក្នុងសេដ្ឋកិច្ចជាតិតាមរយៈការផ្តល់ហិរញ្ញប្បទាន និងឥណទានដល់ការវិនិយោគនានាពិសេសដល់វិស័យផលិតកម្មនៃសហគ្រាសធុនតូច និងមធ្យមដែលជាការជួយបង្កើនសមត្ថភាពផលិតកម្ម ការធ្វើទំនើបកម្ម ផលិតកម្ម

ការធ្វើពិពិធកម្មផលិតកម្ម និងការលើកកម្ពស់ស្តង់ដារផលិតផលកម្ពុជា ដែលជាការរួមចំណែកបង្កើននូវប្រសិទ្ធភាពសេដ្ឋកិច្ច ។ តួនាទីអន្តរការិយកម្មនេះនឹងកាន់តែមានប្រសិទ្ធភាពសេដ្ឋកិច្ចបន្ថែមទៀត ប្រសិនបើប្រជាជនទូទាំងប្រទេសបានចូលរួមប្រើប្រាស់សេវានេះកាន់តែច្រើន ដូចដែលអង្គការសហប្រជាជាតិបាន-ទទួលស្គាល់ថា «**លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុក្នុងតម្លៃសមរម្យដោយប្រជាជនដែលមានចំណូលទាប និងនៅតំបន់ជនបទ គឺមានសារៈសំខាន់ណាស់ ដើម្បីកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍសេដ្ឋកិច្ចឱ្យប្រកបដោយចិរភាព**» ។

កន្លងមក វិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបានចូលរួមចំណែកយ៉ាងខ្លាំងដល់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការលើកស្ទួយកម្រិតជីវភាពរស់នៅរបស់ពួកគាត់ខណៈដែលសេវាហិរញ្ញវត្ថុបានរីករាលដាលយ៉ាងខ្លាំងនៅតាមទីជនបទ ទុនបន្ថែមបានទៅដល់ដៃប្រជាជនដែលមានចំណូលទាប ដែលមានតម្រូវការទុនដើម្បីវិនិយោគ ។ បច្ចុប្បន្ននេះប្រជាជនពេញវ័យដែលកំពុងប្រើប្រាស់សេវាហិរញ្ញវត្ថុផ្លូវការមានប្រមាណ ៥១% នៃប្រជាជនពេញវ័យសរុប ។ តួលេខនេះបានបន្តកើនឡើងគួរឱ្យកត់សម្គាល់បើប្រៀបធៀបនឹងរយៈពេល ១០ ឆ្នាំមុន ។



ជាលទ្ធផល វិស័យនេះបានរួមចំណែកយ៉ាងខ្លាំងដល់ការកាត់បន្ថយអត្រាភាពក្រីក្ររបស់ប្រជាជន គម្លាតរវាងអ្នកមាននិងអ្នកក្រ និងរវាងទីក្រុង និងជនបទ ។ ក្នុងនោះអត្រានៃភាពក្រីក្រត្រូវបានកាត់បន្ថយជាង ១% ក្នុងមួយឆ្នាំ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដែលធ្វើឱ្យអត្រានេះបានធ្លាក់ចុះយ៉ាងលឿនពីជាង ៥៣% ក្នុងឆ្នាំ ២០០៤ មកត្រឹម ១៦% នៅឆ្នាំ ២០១៣ ហើយផលិតផលក្នុងស្រុកសរុប គិតជាមធ្យមសម្រាប់មនុស្សម្នាក់បានកើនពី ៧៦០ ដុល្លារ នៅឆ្នាំ ២០០៨ ដល់ប្រមាណ ១.២២៥ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៥ ដែលធ្វើឱ្យកម្ពុជាកំពុងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប ។

*- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូល*

ក្នុងអំឡុងពេលនៃពិធីបើកសន្និសីទជាតិស្តីពីមីក្រូហិរញ្ញវត្ថុកម្ពុជាកាលពី ឆ្នាំ ២០០៦ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុសាសន៍មួយចំនួន ដើម្បីពង្រឹងប្រតិបត្តិការមីក្រូហិរញ្ញវត្ថុនៅកម្ពុជាឱ្យមានប្រសិទ្ធភាព និងសុខភាពល្អសំដៅរួមចំណែកអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ ខ្ញុំសង្កេតឃើញថា វិស័យមីក្រូហិរញ្ញវត្ថុបានរីកចម្រើនគួរឱ្យកត់សម្គាល់ទាំងទំហំ និងវិសាលភាព ។ ពិតណាស់ថា ការរីកចម្រើននេះក៏មិនអាច

សម្រេចបានដែរ ប្រសិនបើមិនមានបរិយាកាសអំណោយផលពីកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេសការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានធ្វើឱ្យកាន់តែប្រសើរក្នុងការគ្រប់គ្រង និងអនុវត្តនូវគោលនយោបាយសារពើពន្ធរបស់រាជរដ្ឋាភិបាល ។

ជាមួយនេះ ធនាគារជាតិនៃកម្ពុជាតែងបានបន្តកែសម្រួលបទបញ្ញាប្រុងប្រយ័ត្នសម្រាប់ត្រួតពិនិត្យឱ្យស្របតាមការអភិវឌ្ឍន៍នៃទីផ្សារ និងបទដ្ឋានអន្តរជាតិ និងដាក់ឱ្យអនុវត្តប្រកបដោយប្រសិទ្ធភាព ។ ប្រការទាំងនេះបាននាំឱ្យវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាបន្តីរីកចម្រើនគួរឱ្យកត់សម្គាល់ និងត្រូវបានទទួលស្គាល់នៅលើឆាកអន្តរជាតិអំពីភាពរឹងមាំ ទាំងលើផ្នែកក្របខ័ណ្ឌបទប្បញ្ញត្តិភាព-ច្នៃប្រឌិត និងភាពទន់ភ្លន់នៃប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ ។ ក្នុងន័យនេះ ធនាគារជាតិនៃកម្ពុជាតែងបានចូលរួមក្នុងកម្មវិធីចែករំលែកបទពិសោធន៍ស្ដីពីការរៀបចំបទប្បញ្ញត្តិ និងការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ព្រមទាំងកត្តាជោគជ័យនានាដែលទទួលបានកន្លងមកដល់អាជ្ញាធរត្រួតពិនិត្យមួយចំនួន ដូចជា**ធនាគារកណ្ដាលនីហ្សេរីយ៉ា ធនាគារកណ្ដាលឡាវ ធនាគារកណ្ដាលវៀតណាម អាជ្ញាធរត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមីយ៉ាន់ម៉ា** ។ល។ នេះជាមោទនភាពមួយរបស់កម្ពុជាយើងដោយឈរលើកិច្ចខិតខំប្រឹងប្រែងដោយផ្ទាល់របស់យើង ។



ទន្ទឹមនេះ ខ្ញុំសូមជំរុញលើកទឹកចិត្តឱ្យបង្កើតផលិតផលហិរញ្ញវត្ថុថ្មីៗសមស្របជាមួយតម្រូវការរបស់ប្រជាជនក្រីក្រក្រៅពីសេវាឥណទាន ក្នុងនោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក៏ផ្ដល់នូវសេវាផ្សេងៗទៀត ដូចជាសេវាប្រាក់សន្សំ សេវាផ្ទេរប្រាក់ សេវាម៉ាស៊ីនដកប្រាក់ និងដាក់ប្រាក់ស្វ័យប្រវត្តិ សេវាធានារ៉ាប់រងខ្នាតតូច និងសេវាធនាគារចល័តជាដើម ។ សេវាទាំងអស់នេះត្រូវបានផ្ដល់ឱ្យអតិថិជនក្នុងគោលបំណងជួយសម្រួល និងលើកកម្ពស់ស្ថានភាពហិរញ្ញវត្ថុគ្រួសារ ក៏ដូចជាអាជីវកម្មឱ្យកាន់តែប្រសើរឡើងហើយត្រូវបន្តពង្រីកបណ្ដាញប្រតិបត្តិការឱ្យគ្របដណ្ដប់រហូតដល់ថ្នាក់មូលដ្ឋាននៅទូទាំង ២៥ រាជធានី ខេត្ត ។

ដោយឡែក ពាក់ព័ន្ធនឹងការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពធនាគារដោយពុំទាន់មានច្បាប់អនុញ្ញាតនាពេលកន្លងមក មានអង្គការមិនមែនរដ្ឋាភិបាល សមាគម និងឈ្មួញឱ្យខ្ចីចងការប្រាក់ក្រៅប្រព័ន្ធបានចាត់ទុកខ្លួនឯងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្របច្បាប់ ដោយយកអត្រាការប្រាក់កម្ចីខ្ពស់ ប្រើវិធីសាស្ត្រគណនាសងប្រាក់កម្ចីមានលក្ខណៈកេងបន្លំ និងកេងប្រវ័ញ្ច

នីតិវិធីនៃការខ្ចីប្រាក់មានភាពធូររលុង និងឆាប់រហ័ស ដែលកត្តាទាំងនេះបានជំរុញឱ្យប្រជាជនទទួលបានប្រាក់កម្ចីពីប្រភពទាំងនោះភាគច្រើនត្រូវជាប់បន្ទុកបំណុលវ័ន្តក និងគ្មានលទ្ធភាពសងបំណុលវិញ ។ ជាលទ្ធផលទ្រព្យបញ្ចាំ ដែលរួមមានដីធ្លី ផ្ទះសម្បែង ដីស្រែត្រូវបានអង្គការ សមាគម ឬ ឈ្មួញទាំងនោះរឹបអូស ។ លើសពីនេះក៏មានគណបក្សនយោបាយ និងបុគ្គលមួយចំនួនបាន និងកំពុងកេងយកផលចំណេញផ្នែកនយោបាយ ដោយឃោសនាឱ្យប្រជាជនយល់ច្រឡំថាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជាគ្រឹះស្ថានរបស់រដ្ឋ ដូច្នេះប្រាក់ដែលខ្ចីជារបស់រដ្ឋ ហើយជំរុញឱ្យប្រជាជនខ្ចីប្រាក់មិនចាំបាច់សងប្រាក់កម្ចីនោះត្រឡប់វិញទេ ហើយថែមទាំងបានសន្យាថាបើពួកគេឈ្នះឆ្នោតនៅអាណត្តិក្រោយនោះ ពួកគេនឹងលុបចោលប្រាក់កម្ចីទាំងនោះ ។ នេះជាការបំភ្លៃការពិត ជាសកម្មភាពកេងប្រវ័ញ្ច និងបោកប្រាស់ ហើយត្រូវបានបំភ្លឺព្រមទាំងថ្កោលទោសចំពោះអង្គការ សមាគម និងឈ្មួញឱ្យខ្ចីចងការប្រាក់ទាំងនោះឱ្យបញ្ឈប់ជាបន្ទាន់នូវសកម្មភាពបែបនេះ តាមរយៈសេចក្តីថ្លែងការណ៍រួមមួយរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជាកាលពីថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ។



ព្រមជាមួយនេះ ធនាគារជាតិនៃកម្ពុជាកំពុងពិនិត្យលើគុណវុឌ្ឍិភាពត្រឹមត្រូវច្បាស់លាស់ ព្រមទាំងចុះត្រួតពិនិត្យដល់ទីកន្លែងជាមុនដើម្បីជាមូលដ្ឋានក្នុងការសម្រេចផ្តល់ ឬ មិនផ្តល់អាជ្ញាប័ណ្ណ ឬចុះបញ្ជីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ចំពោះមុខនេះ យើងឃើញថាធនាគារជាតិនៃកម្ពុជាបានរួមចំណែកបង្កើនចំណេះដឹងលើការប្រើប្រាស់សេវាហិរញ្ញវត្ថុ ដល់ថ្នាក់មូលដ្ឋាន ដែលធ្វើឱ្យប្រជាជនមានការយល់ដឹងកាន់តែច្រើនក្នុងការស្វែងរកប្រភពហិរញ្ញប្បទានពីធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពិសេសធ្វើឱ្យពួកគេយល់ច្បាស់ថា មីក្រូហិរញ្ញវត្ថុពុំមែនជាសកម្មភាពសប្បុរសធម៌ទេ ។ ជាលទ្ធផលគួរឱ្យកត់សម្គាល់មួយទៀត គឺអត្រាការប្រាក់ឥណទានប្រចាំឆ្នាំរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមាននិន្នាការថយចុះជាបន្តបន្ទាប់ក្នុងរយៈពេលកន្លងមក ដោយបានថយចុះពី ៣៦% ក្នុងឆ្នាំ ២០០៦ មក ៣២% ក្នុងឆ្នាំ ២០០៩ បានថយចុះដល់ ២៧,៥% ក្នុងឆ្នាំ ២០១២ និងរហូតដល់ ២៣,៧% ក្នុងឆ្នាំ ២០១៥ ហើយរំពឹងថា នឹងថយចុះបន្តបន្ទាប់ទៀត ។ ការថយចុះនេះ គឺបណ្តាលមកពីការអនុវត្តន៍យន្តការទីផ្សារដែលលើកទឹកចិត្តឱ្យមានការប្រកួតប្រជែងដោយតម្លាភាពសំដៅពង្រឹងគុណភាពនៃសេវា និងផលិតផលហិរញ្ញវត្ថុ ។

សរុបមក ខ្ញុំកត់សម្គាល់ឃើញថា មានកត្តាសំខាន់ចំនួន ៤ ដែលជាកត្តាពន្លឿនកំណើនវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជាក្នុងនោះមាន ***(១)*.** គោលនយោបាយគាំពារ និងលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ***(២)*.** ក្របខ័ណ្ឌបទប្បញ្ញត្តិ និងការត្រួតពិនិត្យដោយប្រុងប្រយ័ត្នរបស់ធនាគារជាតិនៃកម្ពុជា***(៣)*.** ភាពរស់រវើក និងការច្នៃប្រឌិតរបស់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ និង ***(៤)*.** តម្រូវការ និងការគាំទ្ររបស់អតិថិជន ដោយយល់ឃើញពីសារៈសំខាន់នៃវិស័យមីក្រូហិរញ្ញវត្ថុ ក្នុងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុ ។

*-ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គពិធីទាំងមូល !*

ខ្ញុំសូមបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបាន និងកំពុងបន្តខិតខំប្រឹងប្រែងយ៉ាងពេញទំហឹង ដើម្បីរក្សាស្ថិរភាពហិរញ្ញវត្ថុ ទន្ទឹមគ្នានឹងការជំរុញអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុនិយាយជារួម និងវិស័យមីក្រូហិរញ្ញវត្ថុ និយាយដោយឡែក ដើម្បីចូលរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការដាក់ចេញនូវវិធានការគោលនយោបាយ និងការបង្កនូវបរិស្ថានអំណោយផលដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ជាពិសេសការបន្តប្រកាន់ខ្ជាប់នូវគោលការណ៍គ្រឹះនៃសេដ្ឋកិច្ចទីផ្សារ និងការប្រកួតប្រជែងដោយស្មើភាព ។ ជាក់ស្តែងកម្ពុជាបានអនុម័តជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រ



អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុក្នុងនោះ «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**» បានផ្តោតសំខាន់លើការអភិវឌ្ឍន៍ និងការបង្កើតក្របខ័ណ្ឌច្បាប់ចំពោះវិស័យមីក្រូហិរញ្ញវត្ថុ ក្នុងការកេណ្ឌប្រមូល និងបែងចែកធនធាន ដើម្បីលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ សំដៅទ្រទ្រង់កំណើនសេដ្ឋកិច្ចប្រកបដោយចិរភាព ។

ដោយឡែក សម្រាប់អង្គសន្និសីទថ្ងៃនេះ យើងមិនត្រឹមតែលើកឡើងពីភាពជឿនលឿននៃវិស័យមីក្រូហិរញ្ញវត្ថុប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកយកបញ្ហាប្រឈម តួនាទី និងការធ្វើអន្តរការិយកម្មរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ព្រមទាំងតួនាទីរបស់រាជរដ្ឋាភិបាលពិសេសអាជ្ញាធរពាក់ព័ន្ធនានាក្នុងការគាំទ្រប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ ដើម្បីរិះរកដំណោះស្រាយ សំដៅធ្វើឱ្យប្រតិបត្តិការមីក្រូហិរញ្ញវត្ថុប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព មានសុវត្ថិភាព និងបន្តរួមចំណែកលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុនៅកម្ពុជា ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមលើកឡើងនូវមតិមួយចំនួនដែលជាអនុសាសន៍បន្ថែមទៀតសម្រាប់ជាជំនួយស្មារតី ក្នុងការរួមចំណែកអភិវឌ្ឍវិស័យមីក្រូហិរញ្ញវត្ថុកម្ពុជាឱ្យមានវិសាលភាពកាន់តែទូលាយ កាន់តែមានពិពិធភាព មានតួនាទីកាន់តែស៊ីជម្រៅ ហើយរឹងមាំ និងមានប្រសិទ្ធភាព ដើម្បីបន្តទ្រទ្រង់ដល់កំណើន

សេដ្ឋកិច្ចប្រកបដោយចិរភាព និងចូលរួមកាត់បន្ថយភាពក្រីក្រ របស់ប្រជាជន ដែលក្នុងនោះមាន ៖

***ទី១.*** ធនាគារជាតិនៃកម្ពុជាក្នុងនាមជាអាជ្ញាធរបញ្ញត្តិកម្ម និងត្រួតពិនិត្យចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវបន្តដាក់ចេញនូវក្របខ័ណ្ឌបទប្បញ្ញត្តិ និងការត្រួតពិនិត្យដោយធ្វើការថ្លឹងថ្លែងប្រកបដោយសមភាពបំពេញបន្ថែម និងធ្វើសុខដុមនីយកម្មក្របខណ្ឌគតិយុត្ត ព្រមទាំងការពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍន៍ធនធានមនុស្សឱ្យប្រកបដោយវិជ្ជាជីវៈក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។

***ទី២.*** ធនាគារជាតិនៃកម្ពុជាត្រូវបន្តតាមដាន និងចាត់វិធានការលើអ្នកឱ្យខ្ចីចងការក្រៅប្រព័ន្ធឱ្យបានម៉ឺងម៉ាត់ ។ ក្នុងនោះដែរត្រូវបន្តខិតខំជំរុញសេវាមីក្រូហិរញ្ញវត្ថុតាមថ្លៃ និងលក្ខខណ្ឌកាន់តែមានលក្ខណៈអនុគ្រោះសម្រាប់ប្រជាជនក្រីក្រ ក៏ដូចជាសហគមន៍កសិកម្មសំដៅលើកស្ទួយសេដ្ឋកិច្ចជនបទ ទន្ទឹមនឹងការបន្តពង្រីកការផ្តល់ឥណទានដល់សហគ្រាសធុនតូច និងមធ្យម គាំទ្រដល់ ***«គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥»*** ដែលជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មីរបស់កម្ពុជា ។



***ទី៣.*** ធនាគារជាតិនៃកម្ពុជាត្រូវរៀបចំនូវគោលនយោបាយ ឬ យុទ្ធសាស្ត្រលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងកិច្ចគាំពារអតិថិជនសំដៅធ្វើយ៉ាងណាបង្កភាពងាយស្រួល និងលើកទឹកចិត្តប្រជាជនឱ្យមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទទួលបានសេវាហិរញ្ញវត្ថុក្នុងប្រព័ន្ធ និងធានាថាផលប្រយោជន៍របស់ពួកគាត់ត្រូវបានការពារប្រកបដោយតម្លាភាព ។

***ទី៤.*** ធនាគារជាតិនៃកម្ពុជាត្រូវសហការជាមួយក្រសួងពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំយុវជន និងកីឡាក្នុងការរៀបចំដាក់បញ្ចូលនូវចំណេះដឹងហិរញ្ញវត្ថុទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅតាំងពីថ្នាក់បឋមសិក្សា ឬ មធ្យមសិក្សា ។

***ទី៥.*** ធនាគារជាតិនៃកម្ពុជាត្រូវបន្តរៀបចំកម្មវិធីសិក្ខាសាលា និងវេទិកាថ្នាក់តំបន់ និងថ្នាក់ជាតិ ដើម្បីផ្សព្វផ្សាយជូនសាធារណជនឱ្យជ្រួតជ្រាបបន្ថែមទៀតអំពីប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ និងហានិភ័យផ្សេងៗដែលអាចកើតឡើងពីការប្រើប្រាស់សេវាហិរញ្ញវត្ថុនេះ ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា ដែលបានខិតខំប្រឹងប្រែងរួមចំណែកធ្វើឱ្យវិស័យនេះមានការអភិវឌ្ឍន៍គួរជាទីមោទនៈ និងសូមជូនពរដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជាទាំងអស់ និងដៃគូពាក់ព័ន្ធទាំងអស់នៃវិស័យ

មីក្រូហិរញ្ញវត្ថុកម្ពុជាឱ្យទទួលបាននូវវឌ្ឍនភាព និងជោគជ័យថ្មីៗទៀតក្នុងពេលខាងមុខ ។

ដើម្បីជាការបូកសរុប ខ្ញុំសូមដកស្រង់ពីច្បាប់អរិយសត្ថាសម្រាប់ជាគតិ ដែលចាស់ទុំបរមបូរាណលោកបានអប់រំកូនខ្មែររាប់សតវត្សរ៍មកហើយថា ÷

**វាយលេខទាត់ក្បាច់ សឹងផ្សំសម្រេច**
**ឱ្យបានដឹងដាន ដឹងដើមដឹងចុង**
**ដឹងបង់ដឹងបាន ដឹងគិតប្រមាណ**
**កត់ត្រាបញ្ជី ។**

**ឱ្យបានប្រយោជន៍ ប្រយ័ត្នអសោច**
**ជាអ្នករកស៊ី សម្រាប់លោកិយ**
**ប្រក្រតីជាទី សម្គាល់បញ្ជី**
**ស្មៀនត្រាសៀវភៅ ។**

**គន់គិតប្រយ័ត្ន អស់ទ្រព្យសម្បត្តិ**
**ឱ្យស្ទាត់ដោយនូវ វាយលេខទាត់ក្បាច់**
**ឱ្យស្រេចឃើញផ្លូវ សឹមថយចេញទៅ**
**តាមផ្លូវលោកិយ ។**



ជាទីបញ្ចប់ ជាមួយនឹងការប្រកាសបើក ***«សន្និសីទជាតិស្តីពីការអភិវឌ្ឍន៍នៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា»*** នៅពេលនេះ ខ្ញុំសូមជូនពរចំពោះឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ដែលបានចូលរួមក្នុងសន្និសីទនេះ សូមប្រកបដោយពុទ្ធពរទាំង ៤ ប្រការ ***អាយុ វណ្ណៈ សុខៈ ពលៈ*** កុំបីឃ្លៀងឃ្លាតឡើយ ។

***សូមអរគុណ !***